អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបញ្ចប់សវនាការរយៈពេលពីរថ្ងៃនៅក្នុងសំណុំរឿង ០០៤/០១

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ចប់សវនាការរយៈពេលពីរថ្ងៃនៅក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញារងជាតិ និងសហមេធាវីការពារក្តីជាតិ និងអន្តរជាតិ បានបង្ហាញនូវអំណះអំណាងរបស់ខ្លួននៅក្នុងសំណុំរឿងនេះ។ ជនត្រូវចោទមិនបានចូលរួមក្នុងសវនាការនេះទេ តែត្រូវបានតំណាងដោយសហមេធាវីរបស់គាត់។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ២២ ខែ កុម្ភៈ និងថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ដែលសំណុំរឿងនេះត្រូវបានច្រានចោល ដោយសារ អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គល។

គោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ "គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី០៦ មករា ១៩៧៩"។ អនុលោមតាមដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អ៊ឹម ចែម ស្របទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់បញ្ចូលទៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងចំណោមបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈតួនាទីថ្នាក់ដឹកនាំរបស់គាត់នៅថ្នាក់ស្រុក និងតំបន់ ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ចំណែកឯ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ជនត្រូវចោទមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដើម្បីប្រឈមមុខនឹងការជំនុំជម្រះទោសនោះទេ។

អង្គបុរេជំនុំជម្រះនឹងសម្រេចថា តើមានភស្តុតាងគ្រប់គ្រាន់ដែលថា អ៊ឹម ចែម ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនៃយុត្តាធិការរបស់តុលាការ ឬយ៉ាងណា។ នាពេលនេះ អង្គជំនុំជម្រះនឹងលើកពេលសវនាការដើម្បីពិភាក្សាចេញសេចក្តីសម្រេចរបស់ខ្លួនថាតើនឹងច្រានចោល ឬបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ។ សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយតម្រូវឲ្យមានសំឡេងគាំទ្រចំនួនបួនយ៉ាងតិចក្នុងចំណោមចៅក្រមទាំងប្រាំរូប។ សេចក្តីសម្រេចនេះរំពឹងថា នឹងអាចចេញក្នុងអំឡុងត្រីមាសទីពីរឆ្នាំ ២០១៨ ខាងមុខ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


| | |
|---|---|
| លោកស្រី ហាយ៉ាត់ អាបូសាឡេស | លោក នេត្រ ភក្ត្រា |
| មន្ត្រីផ្នែកកិច្ចការសាធារណៈ | មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម |
| ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ៩៣៦ | ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦ |
| អ៊ីមែល៖ abusaleh@un.org | អ៊ីមែល៖ neth.phektra@eccc.gov.kh |